# I- ទីស្តីការគណៈរដ្ឋមន្ត្រី

## ១- អនុក្រឹត្យ

*រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ១៩៩៤*

**អនុក្រឹត្យលេខ ២៨ អនក្រ**

**ស្តីពីការបង្កើតនាយកដ្ឋានសំភារៈបច្ចេកទេស**

**ចំណុះក្រសួងការពារជាតិ**

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះបាទ សម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះចៅក្រុង កម្ពុជា ធិបតី ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតក្រសួងការពារជាតិ និង អគ្គសេនាធិការ នៃ កងយោធពលខេមរភូមិន្ទ

-យោងតាមសំណើរ របស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

**សំរេច**

មាត្រា ១ : ត្រូវបានបង្កើតនាយកដ្ឋានសំភារៈបច្ចេកទេស ក្រោមការគ្រប់គ្រងបញ្ជាផ្ទាល់ របស់ក្រសួងការពារជាតិ